**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល**
**គណៈកម្មាធិការលទ្ធកម្ម**
**លេខ : ១៧/១៨**

# សេចក្តីជូនដំណឹង
## ស្តីពីការអញ្ជើញចូលរួមដេញថ្លៃ
## ស្តីពីការថែទាំ និងសំអាតអគាររដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល និងអគារមជ្ឈមណ្ឌលហ្វឹកហ្វឺនអាកាសចរស៊ីវិល ប្រចាំឆ្នាំ ២០១៨

រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល)ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជា អោយបានជ្រាបថាៈរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈ ដើម្បីធ្វើការថែទាំនិងសំអាតអគាររដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល និងអគារមជ្ឈមណ្ឌលហ្វឹកហ្វឺនអាកាសចរស៊ីវិល ប្រចាំឆ្នាំ ២០១៨។

រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាស បំពេញដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់នៅអង្គភាពលទ្ធកម្ម នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ដែលមានអាសយដ្ឋានលេខៈ ៤៤, មហាវិថី សហព័ន្ធរុស្ស៊ី,ភូមិ តាងួន, សង្កាត់ កាកាប,ខណ្ឌ ពោធិ៍សែនជ័យ, រាជធានីភ្នំពេញ ចាប់ពីថ្ងៃទី.០៨...ខែវិច្ឆិកា. ឆ្នាំ ២០១៨ តទៅ រៀងរាល់ម៉ោងធ្វើការ( ទូរស័ព្ទទាក់ទងលេខៈ ០២៣ ៨៩០ ១៦៥)។

កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃ នៅម៉ោងៈ០៥ម៉ោងល្ងាច...ថ្ងៃទី.០៧....ខែ..ធ្នូ........ឆ្នាំ២០១៨។

ការបើកសំណើដេញថ្លៃនឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្មតាមអាសយដ្ឋានខាងលើវេលាម៉ោងៈ០៥ម៉ោង៣០...ថ្ងៃទី.០៧.....ខែ....ធ្នូ........ឆ្នាំ ២០១៨។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រកពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ។

ថ្ងៃព្រហស្បតិ៍ ១កើត ខែ...កត្តិក......ឆ្នាំ ច សំរឹទ្ធិស័ក ព.ស ២៥៦២
ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី.០៨.....ខែ..វិច្ឆិកា...ឆ្នាំ ២០១៨

**ប្រធានគណៈកម្មាធិការលទ្ធកម្ម**

**ម៉ៅ ហាវណ្ណាល់**

ចម្លងជូន ៖
-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
-អង្គភាពប្រឆាំងអំពើពុករលួយ
-ឯកសារ-កាលប្បវត្តិ